4

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**

**បន្ទាយមានជ័យ**

**សំណុំរឿងព្រហ្មទណ្ឌលេខ : ១៥៨**

ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១

**សាលក្រមលេខ : ០៩ (ខ)**

ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២

# <u>លិខិតសាលក្រម</u>

**ថ្ងៃបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តបន្ទាយមានជ័យ បានសំរេចចេញសាលក្រមដែលមានគូភាគី**

-ដើមចោទឈ្មោះ [redacted] សុភា ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទឈ្មោះ [redacted] ផល្លា ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទឈ្មោះ [redacted] សុភាព ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទឈ្មោះ [redacted] វីណា ភេទស្រី អាយុ២៦ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ដើមចោទឈ្មោះ [redacted] សុផារី ភេទស្រី អាយុ២៤ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

មេធាវីតំណាងដោយអាណត្តិលោក [redacted]

-និងចុងចម្លើយឈ្មោះ [redacted] ធំនោរ ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ [redacted] ចំណាប់ ហៅ [redacted] ចំណាប់ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ [redacted] រតនះ ភេទប្រុស ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ [redacted] រតនា ភេទប្រុស ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ [redacted] ធីតា ភេទប្រុស ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។



Scanned with CamScanner

-ចុងចម្លើយឈ្មោះ [redacted] ធូនីកា ភេទស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ [redacted] ហ៊ីម ភេទស្រី ឆ្នាំកំណើត១៩៧០ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិរោងម៉ាស៊ីន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ [redacted] សុខា ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិភ្នំតូចខាងជើង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

-ចុងចម្លើយឈ្មោះ [redacted] សារ៉ាយ ហៅ [redacted] សម្បត្តិ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**កម្មវត្ថុ** : សុំតុលាការចេញសាលក្រមសម្រេចអំពី :

១-សុំឱ្យតុលាការបែងចែកឡើងវិញនូវដីកេរ្តិ៍របស់សពឈ្មោះ [redacted] ហួរ មានទំហំ ១២០៧៩ (មួយម៉ឺនពីពាន់សូន្យរយចិបសិបប្រាំបួន) ម៉ែត្រការ៉េ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

## អង្គហេតុ

សពឈ្មោះ [redacted] ហួរ មានប្រពន្ធដើមឈ្មោះ [redacted] ហ៊ាប មានកូនប្រាំមួយនាក់ និងប្រពន្ធចុងឈ្មោះ [redacted] ហឿន មានកូនប្រាំមួយនាក់ ។ការដែលសពលោក [redacted] ហួរ បានរួមរស់នៅជាមួយនិងប្រពន្ធចុងឈ្មោះ [redacted] ហឿន មានដីមួយកន្លែងទំហំ១២០៧៩ម៉ែត្រការ៉េ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងពេលដែលសពលោក [redacted] ហួរ នៅរស់ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០០ បានធ្វើលិខិតផ្ទេរសិទ្ធិដីឱ្យទៅឈ្មោះ [redacted] សារ៉ាយ រួចហើយ ។នៅក្នុងឆ្នាំ២០០៩ ឈ្មោះ [redacted] ហួរ បានទទួលមរណភាពទៅដោយពុំមានធ្វើមតិកសាសន៍អ្វីឡើយ ។ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ ភាគីតំណាងឱ្យខាងប្រពន្ធនិងកូនដើម [redacted] សុភា) និងតំណាងឱ្យខាងប្រពន្ធនិងកូនចុង( [redacted] ជំនោរ) បានចុះកិច្ចព្រមព្រៀងបែងចែកទ្រព្យជាដីស្រែដែលជារបស់មតកជន ហើយបានព្រមព្រៀងគ្នាថាឈប់ប្តឹងផ្តល់គ្នាចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀងនេះតទៅ ស្រាប់តែនៅ១៥-០៧-២០១១ ចុងចម្លើយក៏បានដាក់ពាក្យបណ្តឹងចូលមកតុលាការដើម្បីប្តឹងសុំបែងចែកដីលំនៅឋានទំហំ១២០៧៩ម៉ែត្រការ៉េ ដោយសំអាងថាកាលលើកមុនចែកគ្នាតែដីស្រែទេ ។

## ចំណុចវិវាទ

ដើមចោទនៅតែទាមទារឱ្យបែងចែកដីកេរ្តិ៍របស់ [redacted] ហួរ ទំហំ១២០៧៩ម៉ែត្រការ៉េ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាពីរចំណែកស្មើគ្នា គឺដើមចោទយកពាក់កណ្តាលស្មើនិងទំហំ៦០៣៩ម៉ែត្រការ៉េ និងប្រគល់ឱ្យចុងចម្លើយពាក់កណ្តាលស្មើនិង៦០៣៩ម៉ែត្រការ៉េ តែចុងចម្លើយពុំយល់ព្រមតាមការទាមទាររបស់ដើមចោទ ។

## នាពេលសវនាការ

-ក្រោយពីបាន ស្តាប់ការអះអាងរបស់ដើមចោទ

-ក្រោយពីបាន ស្ដាប់ការអះអាងរបស់ចុងចម្លើយ

-ក្រោយពីបាន ស្ដាប់ការថ្លែងការណ៍របស់មេធាវីការពារឱ្យដើមចោទ

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## ដោយសំអាងហេតុថា

-ការទាមទាររបស់ដើមចោទឈ្មោះ[redacted] សុភា ប្ដឹងសុំឱ្យតុលាការសម្រេចចេញសាលក្រមឱ្យធ្វើការបែងចែកឡើងវិញនូវដីកេរ្តិ៍របស់សពឈ្មោះ[redacted] ហួរ ទំហំ១២០៧៩ម៉ែត្រការ៉េ ឋិតក្នុងភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានធ្វើឡើងត្រឹមត្រូវទៅតាមទម្រង់ច្បាប់ ដែលអាចឱ្យតុលាការលើកយករឿងក្តីនេះមកវិនិច្ឆ័យសម្រេចដល់អង្គសេចក្តីបាន។

-ការទាមទារសុំបែងចែកដីកេរ្តិ៍របស់មតកជនឈ្មោះ[redacted] ហួរ ដែលត្រូវជាឪពុករបស់ខ្លួន របស់ដើមចោទឈ្មោះ[redacted] សុភា ផ្ទុយពីគតិច្បាប់ ពុំអាចឱ្យតុលាការសម្រេចឱ្យបែងចែកដីនេះឡើងវិញបានឡើយ ព្រោះថាថ្វីបើនេះមានមួយចំណែកជាទ្រព្យរួមរវាង[redacted] ហួរ និងប្រពន្ធក្រោយក៏ដោយ ក៏ដីទាំងអស់នេះឈ្មោះ[redacted] ហួរ ពេលនៅរស់បានធ្វើលិខិតផ្ទេរសិទ្ធិទៅឱ្យឈ្មោះ[redacted] សារ៉ាយ ហៅ [redacted] ដាវីត តាំងពីឆ្នាំ២០០០មកម្ល៉េះ ហើយ[redacted] សារ៉ាយបានបែងចែកដីនេះឱ្យទៅប្អូនៗរួចរាល់អស់ហើយ ម្យ៉ាងវិញទៀតតាំងពីពេលដែល[redacted] ហួរ ប្រគល់សិទ្ធិនោះម[redacted] សុភា ពុំបានធ្វើការតវ៉ា ឬទាមទារអ្វីឡើយ លើសពីនេះទៅទៀតក្រោយពេលឈ្មោះ[redacted] ហួរស្លាប់ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ ដើមចោទឈ្មោះ[redacted] សុភា (ជាតំណាងភាគីប្រពន្ធដើម) និង[redacted] ជំនោរ(តំណាងភាគីប្រពន្ធចុង) បានព្រមព្រៀងគ្នាបែងចែកដីស្រែដែលជាកេរអាកររបស់ឈ្មោះ [redacted] ហួរ រួចហើយ ។ថែមទាំងព្រមព្រៀងគ្នាថាឈប់ប្ដឹងផ្តល់គ្នាចាប់ពីថ្ងៃចុះកិច្ចព្រមព្រៀងនោះតទៅទៀតផង។

-រដ្ឋអំណាចឃុំដែលជាអាជ្ញាធរមូលដ្ឋាន លើទីតាំងដីទំនាស់បានអះអាងថាលោក[redacted] ហួរ និងលោកស្រី[redacted] ហឿន (ប្រពន្ធចុង) បានប្រគល់ដីទំនាស់ជូនឈ្មោះ[redacted] សារ៉ាយប្រាកដមែន។

-មតកជនឈ្មោះ[redacted] ហួរ បានធ្វើអនុប្បទានដីទំនាស់ទាំងមូលនៅពេលដែលខ្លួនកំពុងនៅរស់ហើយមានស្មារតីយល់ដឹងច្បាស់លាស់ទោះបីលិខិតផ្ទេរសិទ្ធិនោះពុំត្រឹមត្រូវតាមទម្រង់មតកសាសន៍ក៏ដោយ ក៏អាចបង្ហាញយ៉ាងច្បាស់ពីឆន្ទៈរបស់ម្ចាស់ទ្រព្យ ដូច្នេះផ្អែកតាមមាត្រា ១១៩៥ នៃក្រមរដ្ឋប្បវេណី ទ្រព្យសម្បត្តិនោះត្រូវធ្លាក់ទៅលើឈ្មោះ[redacted] សារ៉ាយ ដោយស្វ័យប្រវត្តិ ក្រោយពេលមតកជនបានទទួលមរណភាពទៅ ដោយពុំអាចសើរើយកមកបែងចែកឡើងវិញបានឡើយ។

-គប្បីសម្រេចច្រានចោលការទាមទាររបស់ដើមចោទ។

-គប្បីសម្រេចរឹបអូសប្រាក់ប្រដាប់ក្ដី។

## ហេតុដូច្នេះសម្រេច :

១/-ច្រានចោលបណ្ដឹងទាមទារសុំឱ្យបែងចែកឡើងវិញនូវដីទំហំ១២០៧៩ម៉ែត្រការ៉េ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ របស់ដើមចោទឈ្មោះ[redacted] សុភ័ក្ត្រា[redacted] ផល្លា[redacted] ផល្លី.[redacted] សុភាព.[redacted] វីណា.[redacted] សុផារី ពីសហចុងចម្លើយឈ្មោះ[redacted] ជំនោរ.[redacted] សារ៉ាយ.[redacted] ចំណាប់.[redacted] រតនះ.[redacted] រតនា[redacted] ធីតា.[redacted] ម៉ូនីកា.[redacted]-ហ៊ីម និងតាំង សុខា ចាប់ពីថ្ងៃសាលក្រមនេះ ចូលជា

ស្អាតរតទៅ។

២/-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

៣/-សាលក្រមនេះ ធ្វើការទាញហេតុផលផ្ទាល់មាត់និងប្រកាសជាសាធារណៈចំពោះមុខភាគីដើមចោទ និងចុងចម្លើយឈ្មោះ[redacted] សារ៉ាយ.[redacted] ឥនះ.[redacted] ចំណាប់.[redacted] សុខា កំបាំងមុខ[redacted] ម៉ូនីកា.[redacted] ធីតា.[redacted] ជំនោរ.[redacted] រតនា និង[redacted] ហ៊ីម តែបាត់មុខទុកដូចជាចំពោះមុខ។ បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ចៅក្រមជំនុំជម្រះ

[redacted]

៤៦៦

466